ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
ក្រុមប្រឹក្សាភិបាលមូលនិធិកាតព្វកិច្ច
សេវាសកលទូរគមនាគមន៍
លេខៈ ០០២/១៩ ក.ម.ក.ស.ទ

# សេចក្តីណែនាំ
# ស្តីពី
# លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការស្នើសុំអនុវត្តគម្រោងអនុវត្តកម្មវិធីកាតព្វកិច្ចសេវាសកលវិស័យទូរគមនាគមន៍ដោយប្រតិបត្តិករទូរគមនាគមន៍ និងបុគ្គលមានគុណវុឌ្ឍិផ្សេងទៀត ដើម្បីផ្តល់ ពង្រឹង និងពង្រីកសេវាទូរគមនាគន៍និងសេវាបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានទំនើបនិងល្បឿនលឿននៅតំបន់អាទិភាព

អនុលោមតាមអនុក្រឹត្យលេខ១១១ អនក្រ.បក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការកំណត់អំពីយន្តការសម្រាប់អនុវត្តកម្មវិធីកាតព្វកិច្ចសេវាសកលវិស័យទូរគមនាគមន៍ ក្រុមប្រឹក្សាភិបាលមូលនិធិកាតព្វកិច្ចសេវាសកលទូរគមនាគមន៍ (ក.ម.ក.ស.ទ.) សូមធ្វើការណែនាំស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការស្នើសុំអនុវត្តគម្រោងអនុវត្តកម្មវិធីកាតព្វកិច្ចសេវាសកល (គម្រោង ក.ស.ទ.) ដោយប្រតិបត្តិករទូរគមនាគមន៍ និងបុគ្គលមានគុណវុឌ្ឍិផ្សេងទៀត ដើម្បីផ្តល់ ពង្រឹង និងពង្រីកសេវាទូរគមនាគមន៍ សេវាបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានទំនើបនិងល្បឿនលឿននៅតំបន់អាទិភាព ដូចខាងក្រោម៖

## ១-ព័ត៌មានទូទៅ

### ១.១. គម្រោងនិងវិសាលភាពការងារដែលអនុញ្ញាតឱ្យធ្វើការស្នើសុំគម្រោង ក.ស.ទ.

ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលមានគុណវុឌ្ឍិ អាចដាក់ពាក្យស្នើសុំអនុវត្តគម្រោង ក.ស.ទ. ដូចខាងក្រោម៖

ក- ការផ្តល់ ការពង្រឹង និងការពង្រីកសេវាទូរគមនាគមន៍និងអ៊ិនធឺណិតល្បឿនលឿន ជាអាទិភាពទៅ៖

- រដ្ឋបាលថ្នាក់ក្រោមជាតិ
- តំបន់ជនបទ
- តំបន់ដែលប្រជាជនមានចំណូលទាបជាងប្រាក់ឈ្នួលអប្បរមាដែលត្រូវបានជានាសម្រាប់កម្មករនិយោជិត
- តំបន់ទេសចរណ៍
- តំបន់ការពារធម្មជាតិ
- តំបន់បេតិកភណ្ឌធម្មជាតិ
- តំបន់ការពារបេតិកភណ្ឌវប្បធម៌
- គ្រឹះស្ថានសិក្សាសាធារណៈ ឬគ្រឹះស្ថានសិក្សាឥតគិតថ្លៃ
- គ្រឹះស្ថានស្រាវជ្រាវសាធារណៈ ឬគ្រឹះស្ថានស្រាវជ្រាវឥតគិតថ្លៃ



អគារលេខ ១៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ.
ទូរស័ព្ទ (៨៥៥) ២៣-៧២៤៨១០/៤២៦៥១០
ទូរសារ (៨៥៥) ២៣-៧២៤០៦៩

- បណ្ណាល័យជាតិ បណ្ណាល័យរាជធានី-ខេត្ត ឬបណ្ណាល័យឥតគិតថ្លៃ
- មន្ទីរពេទ្យសាធារណៈ ឬមន្ទីរពេទ្យឥតគិតថ្លៃ
- មណ្ឌលសុខភាពសាធារណៈ ឬមណ្ឌលសុខភាពឥតគិតថ្លៃ

ខ- ការផ្តល់ ការពង្រឹង និងការពង្រីកសេវាបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានទំនើបនៅតំបន់ ឬទីតាំងអាទិភាព ដែលកំណត់ដោយ ក.ម.ក.ស.ទ. មានជាអាទិ៍៖

- មាតិកាព័ត៌មានឬកម្មវិធីសូហ្វវែរដែលចូលរួមចំណែកការកាត់បន្ថយគម្លាតឌីជីថល ការអភិវឌ្ឍវិស័យ ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍជនបទ
- មាតិកាព័ត៌មានឬកម្មវិធីសូហ្វវែរដែលអាចចូលរួមចំណែកការអភិវឌ្ឍន៍ ស្របតាមគោលដៅអភិវឌ្ឍន៍ ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ

គ- ការផ្តល់សេវាគ្រាអាសន្នទូទាំងប្រទេសដោយឥតគិតថ្លៃ។

**១.២. ទីតាំងនៃគម្រោងដែលអនុញ្ញាតឱ្យស្នើសុំគម្រោង ក.ស.ទ.**

ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលមានគុណវុឌ្ឍិ អាចដាក់ពាក្យស្នើសុំអនុវត្តគម្រោង ក.ស.ទ. ដូចកំណត់ក្នុងចំណុច ១(ក)និង១(ខ) ខាងលើ នៅក្នុងតំបន់ ឬទីតាំងអាទិភាព ដែលកំណត់ដោយ ក.ម.ក.ស.ទ. ប៉ុណ្ណោះ។

ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលមានគុណវុឌ្ឍិ អាចដាក់ពាក្យស្នើសុំអនុវត្តគម្រោង ក.ស.ទ. ដូចកំណត់ក្នុងចំណុច ១(គ) នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

## ២-លក្ខខណ្ឌនិងបែបបទនៃការស្នើសុំគម្រោង ក.ស.ទ.

### ២.១-លក្ខខណ្ឌនៃការស្នើសុំ

បុគ្គលដែលមានបំណងស្នើសុំអនុវត្តគម្រោង ក.ស.ទ. ត្រូវបំពេញលក្ខខណ្ឌដូចតទៅ៖

#### ២.១.១-ការផ្តល់ ការពង្រឹង និងការពង្រីកសេវាទូរគមនាគមន៍និងអ៊ីនធឺណិតល្បឿនលឿន

- ជាប្រតិបត្តិករទូរគមនាគមន៍ ដែលពុំមានជាប់បំណុលដោយខកខានក្នុងការបង់វិភាគទានចូលមូលនិធិ ក.ស.ទ.
- មានសក្តានុពលភាពផ្នែកបច្ចេកទេស និងមានឆន្ទៈក្នុងការសម្រេចនូវគម្រោងអនុវត្តកម្មវិធី ក.ស.ទ.
- មានអាជ្ញាបណ្ណប្រតិបត្តិការលើវិស័យទូរគមនាគមន៍

#### ២.១.២-ការផ្តល់ ការពង្រឹង និងការពង្រីកសេវាបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានទំនើប

- ជាប្រតិបត្តិករទូរគមនាគមន៍៖
  - ដែលពុំមានជាប់បំណុលដោយខកខានក្នុងការបង់វិភាគទានចូលមូលនិធិ ក.ស.ទ.
  - មានអាជ្ញាបណ្ណប្រតិបត្តិការលើវិស័យទូរគមនាគមន៍
- អង្គភាពរដ្ឋទទួលបន្ទុកអភិវឌ្ឍន៍វិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឬ
- អង្គភាពរដ្ឋដែលជំរុញការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានក្នុងការកាត់បន្ថយគម្លាតឌីជីថល និង/ឬជំរុញការបង្កើតមាតិកាឌីជីថល
- មានឆន្ទៈក្នុងការសម្រេចនូវគម្រោងអនុវត្តកម្មវិធី ក.ស.ទ.

### ២.១.៣-ការផ្តល់សេវាគ្រាអាសន្ន

- ជាប្រតិបត្តិករទូរគមនាគមន៍៖
  - ដែលពុំមានជាប់បំណុលដោយខកខានក្នុងការបង់ភាគទានចូលមូលនិធិ ក.ស.ទ.
  - មានអាជ្ញាបណ្ណប្រតិបត្តិការលើវិស័យទូរគមនាគមន៍
- អង្គភាពរដ្ឋទទួលបន្ទុកអភិវឌ្ឍន៍វិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឬ
- អង្គភាពរដ្ឋដែលជំរុញការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានក្នុងការកាត់បន្ថយគម្លាតឌីជីថល និង/ឬជំរុញការបង្កើតមាតិកាឌីជីថល
- មានឆន្ទៈក្នុងការសម្រេចនូវគម្រោងអនុវត្តកម្មវិធី ក.ស.ទ.។

### ២.២-បែបបទនៃការស្នើសុំគម្រោង ក.ស.ទ.

បុគ្គលដែលមានបំណងស្នើសុំគម្រោង ក.ស.ទ. ដូចកំណត់ក្នុងចំណុច ១(ក),១(ខ)និង១(គ) ខាងលើ ត្រូវដាក់ពាក្យស្នើសុំគម្រោង ក.ស.ទ. មកលេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ ដោយត្រូវផ្តល់នូវឯកសារនិងព័ត៌មាន ដូចខាងក្រោម៖

- ពាក្យស្នើសុំគម្រោង ក.ស.ទ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី១នៃសេចក្តីណែនាំនេះ
- អាជ្ញាបណ្ណប្រតិបត្តិការពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ ចំពោះប្រតិបត្តិករទូរគមនាគមន៍
- លក្ខន្តិកៈក្រុមហ៊ុន
- ផែនការអនុវត្តគម្រោង ផែនការបច្ចេកទេស និងផែនការហិរញ្ញវត្ថុ
- ឯកសារពាក់ព័ន្ធផ្សេងទៀតដូចបានកំណត់ក្នុងខ្លឹមសារ និងឧបសម្ព័ន្ធនៃសេចក្តីណែនាំនេះ។

ក្នុងករណីមានការស្នើសុំពីបុគ្គលច្រើន ក្នុងការអនុវត្តគម្រោងមួយឬច្រើនរួមគ្នា ត្រូវភ្ជាប់មកជាមួយនូវកិច្ចសន្យាស្តីពីការអនុវត្តគម្រោងរួមគ្នា រួមទាំងត្រូវកំណត់អំពីបុគ្គលជាតំណាងក្នុងការទទួលខុសត្រូវអនុវត្តគម្រោងឱ្យបានច្បាស់លាស់។

## ៣-នីតិវិធីនៃការស្នើសុំគម្រោង និងការសម្រេចលើការស្នើសុំគម្រោង ក.ស.ទ.

ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលមានគុណវុឌ្ឍិ ដែលមានបំណងស្នើសុំគម្រោង ក.ស.ទ. ត្រូវគោរពតាមនីតិវិធី និងពេលវេលាកំណត់ដូចខាងក្រោម៖

### ៣.១-នីតិវិធីនិងកាលបរិច្ឆេទសំខាន់ៗពាក់ព័ន្ធនឹងការស្នើសុំអនុវត្តគម្រោង ក.ស.ទ. ត្រូវកំណត់ដូចខាងក្រោម៖

| ដំណាក់កាល | ដំណើរការ | កាលបរិច្ឆេទ |
|---|---|---|
| ១ | ការដាក់ពាក្យស្នើសុំអនុវត្តគម្រោង ក.ស.ទ. | -លើកទី១៖ យ៉ាងយូរត្រឹមថ្ងៃទី៣០ ខែមីនា<br>-លើកទី២៖ យ៉ាងយូរត្រឹមថ្ងៃទី៣០ ខែមិថុនា ឬ<br>-យ៉ាងយូរ ៦០ថ្ងៃ បន្ទាប់ពីការប្រកាសអំពីការដាក់ឱ្យស្នើសុំអនុវត្តគម្រោង ក.ស.ទ. |
| ២ | ការពិនិត្យពាក្យស្នើសុំ និងឯកសារពាក់ព័ន្ធ | ០៥ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីទទួលពាក្យស្នើសុំ |

| | | |
|---|---|---|
| ៣ | ការពិនិត្យ ការវាយតម្លៃ និងរៀបចំរបាយការណ៍លើការស្នើសុំអនុវត្តគម្រោង ក.ស.ទ. ដោយលេខាធិការដ្ឋាន | យ៉ាងយូរ ៣០ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានឯកសារពេញលេញ |
| ៤ | ការពិនិត្យនិងការសម្រេចលើការស្នើសុំអនុវត្តគម្រោងក.ស.ទ. ដោយ ក.ម.ក.ស.ទ. | យ៉ាងយូរ ១០ ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបញ្ចប់ការពិនិត្យ ការវាយតម្លៃ និងរៀបចំរបាយការណ៍លើការស្នើសុំអនុវត្តគម្រោង ក.ស.ទ. |
| ៥ | បុគ្គលដែលទទួលបានការសម្រេចផ្តល់ការអនុវត្តគម្រោង ក.ស.ទ. ត្រូវចាប់ផ្តើមការងារអនុវត្តគម្រោងនិងត្រូវរាយការណ៍ជាប្រចាំខែមកលេខាធិការដ្ឋាន | យ៉ាងយូរ ២០ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានសេចក្តីសម្រេចស្តីពីការផ្តល់គម្រោង ក.ស.ទ. |

**៣.២-នីតិវិធីនៃការស្នើសុំគម្រោង ក.ស.ទ.**

ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលមានគុណវុឌ្ឍិ ដែលមានបំណងស្នើសុំអនុវត្តគម្រោង ក.ស.ទ. ត្រូវដាក់ឯកសារពាក់ព័ន្ធនានា ដូចមានកំណត់ក្នុងចំណុច ២.២ នៃសេចក្តីសម្រេចនេះ មកលេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. ដូចខាងក្រោម៖

- លើកទី១៖ យ៉ាងយូរត្រឹមថ្ងៃទី៣០ ខែមីនា នៃឆ្នាំនីមួយៗ
- លើកទី២៖ យ៉ាងយូរត្រឹមថ្ងៃទី៣០ ខែមិថុនា នៃឆ្នាំនីមួយៗ ឬ
- យ៉ាងយូរត្រឹម ៦០ (ហុកសិប)ថ្ងៃបន្ទាប់ពីលេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. ប្រកាសអំពីការដាក់ឱ្យស្នើសុំអនុវត្តគម្រោង ក.ស.ទ.។ រយៈពេលនេះមិនអាចពន្យាបានទេ។

**៣.៣-ការពិនិត្យ ការវាយតម្លៃ និងការសម្រេច**

ក្នុងរយៈពេល០៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីទទួលពាក្យស្នើសុំអនុវត្តគម្រោង ក.ស.ទ. លេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. ត្រូវពិនិត្យជាបឋមលើពាក្យស្នើសុំនិងឯកសារពាក់ព័ន្ធដើម្បីឱ្យប្រាកដថា បុគ្គលដាក់ពាក្យស្នើសុំបានបំពេញតាមលក្ខខណ្ឌត្រឹមត្រូវ។ លេខាធិការដ្ឋាននៃ **ក.ម.ក.ស.ទ.** អាចស្នើសុំឯកសារបន្ថែម ក្នុងករណីបុគ្គលដាក់ពាក្យស្នើសុំ បានដាក់ឯកសារមិនទាន់គ្រប់គ្រាន់ ឬស្នើសុំការបញ្ជាក់បន្ថែមផ្សេងៗ។

បន្ទាប់ពីទទួលបានឯកសារគ្រប់គ្រាន់ លេខាធិការដ្ឋាននៃ **ក.ម.ក.ស.ទ.** ត្រូវពិនិត្យ វាយតម្លៃ និងរៀបចំរបាយការណ៍និងលើកយោបល់លើការស្នើសុំអនុវត្តគម្រោង ក.ស.ទ. ស្របតាមសេចក្តីណែនាំនេះក្នុងរយៈពេលយ៉ាងយូរ ៣០(សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានឯកសារពេញលេញ ជូន **ក.ម.ក.ស.ទ.** ដើម្បីពិនិត្យនិងសម្រេច។

**៣.៤-នីតិវិធីនៃការពិនិត្យនិងសម្រេចលើការស្នើសុំគម្រោង ក.ស.ទ.**

បន្ទាប់ពីលេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. បានបញ្ចប់នូវរបាយការណ៍ស្តីពីការពិនិត្យនិងវាយតម្លៃលើការស្នើសុំអនុវត្តគម្រោង ក.ស.ទ. ក្នុងរយៈពេលយ៉ាងយូរ ២០ (ម្ភៃ) ថ្ងៃនៃថ្ងៃធ្វើការ ក.ម.ក.ស.ទ. នឹងរៀបចំកិច្ចប្រជុំដើម្បីពិនិត្យនិងសម្រេចលើការស្នើសុំគម្រោង ក.ស.ទ. ដោយពិចារណាលើចំណុចជាអាទិ៍៖

- ទីតាំងនៃគម្រោង ក.ស.ទ. ដែលបានស្នើសុំ (ជាតំបន់អាទិភាព)

- គោលបំណងនិងភាពចាំបាច់នៃគម្រោង
- ផលប៉ះពាល់ជាវិជ្ជមានរបស់គម្រោង
- ស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព
- ភាពត្រឹមត្រូវនិងច្បាស់លាស់នៃផែនការបច្ចេកទេសនិងហិរញ្ញវត្ថុ និងឯកសារពាក់ព័ន្ធផ្សេងទៀត ដែលត្រូវបានភ្ជាប់មកជាមួយនឹងពាក្យស្នើសុំគម្រោង ក.ស.ទ.
- លទ្ធភាពនិងសមត្ថភាពបច្ចេកទេសនិងហិរញ្ញវត្ថុរបស់បុគ្គលដាក់ពាក្យស្នើសុំគម្រោង ក.ស.ទ. ក្នុងករណីបុគ្គលជាប្រតិបត្តិករទូរគមនាគមន៍
- ប្រវត្តិនិងបទពិសោធន៍របស់បុគ្គលដាក់ពាក្យស្នើសុំគម្រោង ក.ស.ទ.
- ចំណុចផ្សេងទៀតដែល ក.ម.ក.ស.ទ. យល់ថាមានសារសំខាន់។

ការសម្រេចផ្តល់គម្រោង ក.ស.ទ. ត្រូវធ្វើឡើងតាមរយៈសេចក្តីសម្រេចរបស់ ក.ម.ក.ស.ទ. ដោយមានការបញ្ជាក់អំពីវិសាលភាពនៃគម្រោងនិងគម្រោងថវិកាដែលត្រូវអនុវត្តគម្រោង ក.ស.ទ.។

**៣.៥-នីតិវិធីនៃការងារអនុវត្តគម្រោង ក.ស.ទ.**

ក្នុងរយៈពេលយ៉ាងយូរ ២០ (ម្ភៃ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានសេចក្តីសម្រេចស្តីពីការផ្តល់គម្រោង ក.ស.ទ. បុគ្គលដែលទទួលបានការអនុវត្តគម្រោង ក.ស.ទ. ត្រូវចាប់ផ្តើមការងារអនុវត្តគម្រោង និងត្រូវរាយការណ៍ជាប្រចាំអំពីវឌ្ឍនភាពការងាររបស់ខ្លួន នៅរៀងរាល់ថ្ងៃទី១០ នៃខែនីមួយៗ ឬតាមការស្នើសុំរបស់លេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ.។

## ៤-វិធាននៃការទូទាត់

បន្ទាប់ពីការសម្រេចអនុម័តលើគម្រោង ក.ស.ទ. លេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. ត្រូវធ្វើការពិនិត្យ និងធ្វើការទូទាត់ដល់បុគ្គលទទួលបានគម្រោង ក.ស.ទ. ដូចខាងក្រោមៈ

**៤.១-ការទូទាត់**

គម្រោងដែលបានអនុម័តនឹងត្រូវទូទាត់ជា៣(បី)ដំណាក់កាលដូចខាងក្រោមៈ

- ធ្វើការទូទាត់ចំនួន៤០% (សែសិបភាគរយ) នៃថវិកាគម្រោងសរុប នៅពេលគម្រោងត្រូវបានអនុម័តប្រគល់ជូន និងបន្ទាប់ពីមានការស្នើសុំពីបុគ្គលអនុវត្តគម្រោង
- ធ្វើការទូទាត់ចំនួន៤០% (សែសិបភាគរយ) ទៀត នៅពេលគម្រោងអនុវត្តបានចំនួន៥០% (ហាសិបភាគរយ) និង
- ធ្វើការទូទាត់ចំនួន ២០% (ម្ភៃភាគរយ) ទៀត នៅពេលគម្រោងអនុវត្តបាន១០០% (មួយរយភាគរយ)។

លើកលែងមានការសម្រេចផ្សេងដោយប្រធាន ក.ម.ក.ស.ទ. តាមការស្នើសុំពីប្រធានលេខាធិការដ្ឋានតាមរយៈអនុប្រធានទាំងពីរនៃ ក.ម.ក.ស.ទ.។

**៤.២-នីតិវិធីនៃការទូទាត់**

ការទូទាត់ត្រូវធ្វើឡើងតាមនីតិវិធីដូចខាងក្រោមៈ

- បុគ្គលដែលទទួលបានការអនុវត្តគម្រោង ក.ស.ទ. ត្រូវផ្ញើរបាយការណ៍វឌ្ឍនភាព និងឯកសារដែលពាក់ព័ន្ធតាមការស្នើសុំរបស់លេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ ព្រមទាំងចូលរួមសហការជាមួយលេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. ដើម្បីពិនិត្យនិងផ្ទៀងផ្ទាត់ទំហំការងារដែលបានសម្រេច
- លេខាធិការដ្ឋានធ្វើការរៀបចំឯកសារទូទាត់ដោយផ្អែកលើ របាយការណ៍វឌ្ឍនភាពការងារពីក្រុមការងារ

ចុះពិនិត្យជាក់ស្តែងនិងផ្ទៀងផ្ទាត់ឯកសារហិរញ្ញវត្ថុដែលបានផ្តល់ដោយប្រតិបត្តិករ

- ក្នុងករណីដែលពិនិត្យទៅឃើញថាការស្នើសុំទូទាត់ត្រឹមត្រូវ លេខាធិការដ្ឋានត្រូវរៀបចំការទូទាត់ជូនបុគ្គលដែលទទួលបានការអនុវត្តគម្រោង ក.ស.ទ.។

## ៥-ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ

លេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. ត្រូវធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃចំពោះការអនុវត្តគម្រោង ក.ស.ទ. ដែលត្រូវបានអនុម័តដោយ ក.ម.ក.ស.ទ.។

លេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. ត្រូវធ្វើរបាយការណ៍ជាប្រចាំជូន ក.ម.ក.ស.ទ. នូវលទ្ធផលនៃការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃលើដំណើរការស្ថាបនាគម្រោង ក.ស.ទ. និងប្រតិបត្តិការនៃការគ្រប់គ្រងនិងការប្រើប្រាស់ផលនៃគម្រោង ក.ស.ទ.។

បុគ្គលដែលទទួលបានការអនុវត្តគម្រោង ក.ស.ទ. ត្រូវផ្តល់របាយការណ៍វឌ្ឍនភាពការងារ និងឯកសារពាក់ព័ន្ធផ្សេងៗជាប្រចាំ ឬតាមការស្នើសុំរបស់លេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ.។ របាយការណ៍វឌ្ឍនភាពការងារនិងឯកសារពាក់ព័ន្ធនេះ ត្រូវផ្តល់មកទាំងឯកសារក្នុងទម្រង់ជាក្រដាស់ (Hard copy) ដែលដាក់ចំណងជើង កាលបរិច្ឆេទ និងមានចុះហត្ថលេខារបស់អ្នកទទួលខុសត្រូវនិងត្រូវប្រថាប់ត្រារបស់បុគ្គលដែលទទួលបានការអនុវត្តគម្រោង ក.ស.ទ. ឱ្យបានច្បាស់លាស់ និងជាឯកសារក្នុងទម្រង់ជាឌីជីថល (Soft copy) ដោយមានចំណងជើងនិងកាលបរិច្ឆេទច្បាស់លាស់។

លេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. ត្រូវរៀបចំរបាយការណ៍ជូន ក.ម.ក.ស.ទ. ដើម្បីពិនិត្យនិងសម្រេចជាផ្លូវការអំពីការបញ្ចប់ជាស្ថាពរដោយជោគជ័យនៃគម្រោងដែលត្រូវបានប្រគល់ជូន។

ការទទួលស្គាល់អំពីការបញ្ចប់ជាស្ថាពរដោយជោគជ័យនៃគម្រោង ក.ស.ទ. ដែលបានប្រគល់ជូនបុគ្គលដែលទទួលបានការអនុវត្តគម្រោង ក.ស.ទ. ត្រូវធ្វើឡើងតាមរយៈសេចក្តីសម្រេចរបស់ ក.ម.ក.ស.ទ. ដោយបញ្ជាក់ផងដែរនូវសិទ្ធិនៃការគ្រប់គ្រងនិងប្រើប្រាស់ផលដែលកើតឡើងពីការអនុវត្តគម្រោង ក.ស.ទ.។

## ៦-ការស្នើសុំពន្យាពេលអនុវត្តគម្រោងនិងការបង់ប្រាក់ពិន័យក្នុងករណីយឺតយ៉ាវ

ក្នុងករណីចាំបាច់ បុគ្គលដែលទទួលបានការអនុវត្តគម្រោង ក.ស.ទ អាចស្នើសុំពន្យារយៈពេលអនុវត្តគម្រោង ក.ស.ទ. ជាលាយលក្ខណ៍អក្សរ មកលេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. ដោយបញ្ជាក់អំពីមូលហេតុដែលមានមូលដ្ឋាននិងហេតុផលច្បាស់លាស់។

លេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. អាចធ្វើការសម្រេចអនុញ្ញាតពន្យាពេលអនុវត្តគម្រោងក្នុងរយៈពេលសរុបមិនលើសពីពាក់កណ្តាលនៃរយៈពេលសរុបនៃការអនុវត្តគម្រោង ដល់ប្រតិបត្តិករទូរគមនាគមន៍ដែលបានស្នើសុំពន្យាពេល ដោយផ្អែកលើមូលហេតុដូចខាងក្រោម៖

- ដោយសារមានករណីប្រធានសក្តិ
- បុគ្គលដែលទទួលបានការអនុវត្តគម្រោង ក.ស.ទ. បានខិតខំអនុវត្តនិងចាត់វិធានការសមស្របដើម្បីជៀសវាងការពន្យាពេលឬកាត់បន្ថយការពន្យាពេល និងបានចាត់វិធានការសមស្របដើម្បីបន្តការងារ
- ការពន្យាពេលមិនមែនកើតឡើងពីការធ្វេសប្រហែស ឬការមិនអនុវត្តឱ្យបានពេញលេញនិងត្រឹមត្រូវរបស់បុគ្គលដែលទទួលបានការអនុវត្តគម្រោង ក.ស.ទ. ។

លេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. មិនត្រូវអនុញ្ញាតឱ្យមានការពន្យាពេលក្នុងការអនុវត្តគម្រោងដល់បុគ្គលដែលទទួលបានការអនុវត្តគម្រោង ក.ស.ទ. ឡើយ ក្នុងករណីដែលការពន្យាពេលអនុវត្តគម្រោងនេះនាំឱ្យការអនុវត្តគម្រោងត្រូវបរាជ័យ ឬមានផលប៉ះពាល់ជាអវិជ្ជមានយ៉ាងធ្ងន់ធ្ងរដល់ផ្នែកផ្សេងទៀតនៃគម្រោង។

លេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. ត្រូវរាយការណ៍ជូន ក.ម.ក.ស.ទ. អំពីការសម្រេចអនុញ្ញាតពន្យាពេល ឬការសម្រេចមិនអនុញ្ញាតពន្យាពេលដល់ប្រតិបត្តិករទូរគមនាគមន៍ដែលទទួលបានគម្រោង ក.ស.ទ.។

ត្រូវចាត់ទុកជាការយឺតយ៉ាវក្នុងការអនុវត្តគម្រោង ក.ស.ទ. ក្នុងករណីដែលបុគ្គលដែលទទួលបានការអនុវត្តគម្រោង ក.ស.ទ. មិនបានបញ្ចប់គម្រោងក្នុងរយៈពេលយ៉ាងយូរ ១០ (ដប់) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទបញ្ចប់គម្រោងដូចមានកំណត់ក្នុងកាលវិភាគនៃការអនុវត្តគម្រោងដែលបានផ្តល់មកលេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. និងមិនមានការអនុញ្ញាតពន្យាពេលអនុវត្តពីលេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ.។ បុគ្គលដែលទទួលបានការអនុវត្តគម្រោង ក.ស.ទ. ដែលបានយឺតយ៉ាងក្នុងការអនុវត្តគម្រោងនេះ ត្រូវបង់ប្រាក់ពិន័យនៃការយឺតយ៉ាវចំនួន ១% (មួយភាគរយ) នៃតម្លៃគម្រោងសរុបចំពោះការយឺតយ៉ាវក្នុងពេលមួយថ្ងៃ។ ការបង់ប្រាក់ពិន័យនៃការយឺតយ៉ាវមិនអាចលើសពី ១៥ (ដប់ប្រាំ) ថ្ងៃបានឡើយ ទោះបីបុគ្គលដែលបានទទួលការអនុវត្តគម្រោង ក.ស.ទ. បានយឺតយ៉ាវក្នុងការអនុវត្តគម្រោងលើសពី ១៥ (ដប់ប្រាំ) ថ្ងៃក៏ដោយ។

ក្នុងករណីដែលបុគ្គលដែលទទួលបានការអនុវត្តគម្រោង ក.ស.ទ. យឺតយ៉ាវក្នុងការអនុវត្តគម្រោងលើសពី ០១ (មួយ)ខែដោយពុំមានការអនុញ្ញាតពន្យាពេល លេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. ត្រូវរាយការណ៍ទៅ ក.ម.ក.ស.ទ. ដើម្បីពិនិត្យនិងសម្រេចដកហូតសិទ្ធិក្នុងការអនុវត្តគម្រោងដែលទទួលបាន និងអាចប្រគល់គម្រោងនោះទៅឱ្យប្រតិបត្តិករទូរគមនាគមន៍ផ្សេងទៀត ព្រមទាំងកំណត់នូវសំណងតាមទំហំនៃព្យសនកម្មដែលកើតមាន។

## ៧-ការធានាចំពោះការអនុវត្តគម្រោង ក.ស.ទ.

### ៧.១-ការសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធ

បុគ្គលដែលទទួលបានការអនុវត្តគម្រោង ក.ស.ទ. ត្រូវសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច លើការងារដូចខាងក្រោម៖

- ស្នើសុំការអនុញ្ញាតពីរដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានសមត្ថកិច្ច មុននឹងចាប់ផ្តើមអនុវត្តការងារ
- ទទួលខុសត្រូវក្នុងការបំពេញលក្ខខណ្ឌនិងការចំណាយនានា ដើម្បីទទួលបានការអនុញ្ញាតពីរដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានសមត្ថកិច្ច
- ទទួលខុសត្រូវរាល់ការចំណាយបន្ថែមផ្សេងៗ ដែលកើតឡើងក្នុងករណីនៃតម្រូវការនៃការផ្លាស់ប្តូរទីតាំងដែលកើតចេញការមិនបំពេញបាននូវលក្ខខណ្ឌ ដែលតម្រូវដោយរដ្ឋបាលថ្នាក់ជាតិឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

### ៧.២-ការធានាសុវត្ថិភាពក្នុងការសាងសង់និងដំណើរការ

បុគ្គលដែលទទួលបានការអនុវត្តគម្រោង ក.ស.ទ. ត្រូវធានានូវសុវត្ថិភាពក្នុងការសាងសង់និងដំណើរការនៃគម្រោង ដូចខាងក្រោម៖

- ទទួលខុសត្រូវក្នុងការអនុវត្តរាល់វិធានការសមស្របនៅគ្រប់ពេលវេលា ក្នុងការធានាសុវត្ថិភាពនៃបុគ្គលនិងទ្រព្យសម្បត្តិនៅក្នុងទីតាំងនៃការអនុវត្តគម្រោង
- អនុវត្តរាល់វិធានការសមស្របនិងអនុវត្តតាមវិធានការសុវត្ថិភាពទាំងឡាយរបស់កម្មករ អ្នកទទួលការ

និងបុគ្គលដទៃទៀតនៅទីតាំងនៃការអនុវត្តគម្រោង ដូចបានកំណត់ក្នុងច្បាប់និងបទប្បញ្ញត្តិជាធរមាន។

## ៨-ការធានាចំពោះគម្រោងដែលបានបញ្ចប់

### ៨.១-ការធានាចំពោះផលនៃគម្រោង ក.ស.ទ.

បុគ្គលដែលទទួលបានការអនុវត្តគម្រោង ក.ស.ទ. ត្រូវធ្វើការធានាចំពោះគុណភាព បរិមាណ រយៈពេលប្រើប្រាស់ និងលក្ខណៈបច្ចេកទេសនៃផលដែលកើតចេញពីការអនុវត្តគម្រោង ក.ស.ទ. ស្របតាមកិច្ចសន្យាផ្តល់ការអនុវត្តគម្រោង ក.ស.ទ. រវាងលេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. ជាមួយនឹងបុគ្គលដែលទទួលបានការអនុវត្តគម្រោង ក.ស.ទ.។

### ៨.២-ការធានាចំពោះគុណភាព

បុគ្គលដែលទទួលបានការអនុវត្តន៍គម្រោងក.ស.ទ. ត្រូវធានាចំពោះគុណភាពនៃមាតិកាព័ត៌មាននិងសេវាដូចបានកំណត់នៅក្នុងកិច្ចសន្យាស្របតាមការកំណត់របស់ច្បាប់ និងបទប្បញ្ញតិជាធរមាននិងត្រូវអនុវត្តឱ្យបានត្រឹមត្រូវនូវកិច្ចការពារអ្នកប្រើប្រាស់ស្របតាមការកំណត់របស់ច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

### ៨.៣-ការតាមដានការអនុវត្តរបស់បុគ្គលដែលទទួលបានសិទ្ធិគ្រប់គ្រងនិងប្រើប្រាស់ផល ដែលកើតចេញពីការអនុវត្តគម្រោង ក.ស.ទ.

លេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. មានសិទ្ធិក្នុងការតាមដាន ការត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តកាតព្វកិច្ចទាំងអស់របស់បុគ្គលដែលទទួលបានសិទ្ធិគ្រប់គ្រងនិងប្រើប្រាស់ផលដែលកើតចេញពីការអនុវត្តគម្រោង ក.ស.ទ. ដូចខាងក្រោម ៖

- ធ្វើការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃទៅលើឯកសារនិងចុះផ្ទាល់ទៅដល់ទីតាំងនៃគម្រោង ដើម្បីបញ្ជាក់អំពីការអនុវត្តរបស់ប្រតិបត្តិករទូរគមនាគមន៍ដែលទទួលបានសិទ្ធិគ្រប់គ្រងនិងប្រើប្រាស់ផលដែលកើតចេញពីការអនុវត្តគម្រោង ក.ស.ទ. ពិតជាគោរពតាមកាតព្វកិច្ចជាអាទិ៍ ទីតាំង គុណភាព បរិមាណ ពេលវេលា និងលក្ខណៈបច្ចេកទេសដែលបានកំណត់ក្នុងសេចក្តីណែនាំនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត
- ធ្វើការត្រួតពិនិត្យ និងពិនិត្យមើលហិរញ្ញវត្ថុតាមរយៈការផ្ទៀងផ្ទាត់រាល់ឯកសារហិរញ្ញវត្ថុនិងឯកសារពាក់ព័ន្ធ ដែលផ្តល់ឱ្យដោយបុគ្គលដែលទទួលសិទ្ធិគ្រប់គ្រងនិងប្រើប្រាស់ផលដែលកើតចេញពីការអនុវត្តគម្រោង ក.ស.ទ. ។ដ

ថ្ងៃ សុក្រ ៤កើត ខែ មាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ២០១៩

**ជ.ក្រុមប្រឹក្សាភិបាលមូលនិធិកាតព្វកិច្ច**

**សេវាសកលទូរគមនាគមន៍**

**ប្រធាន**

**ត្រាំ អ៊ីវតឹក**

**កន្លែងទទួល**

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- លេខាធិការដ្ឋាននៃក្រុមប្រឹក្សាភិបាលមូលនិធិកាតព្វកិច្ចសេវាសកលទូរគមនាគមន៍